THE SCHOOL DISTRICT OF PHILADELPHIA

**OFFICE OF THE SUPERINTENDENT**
440 North Broad Street
Philadelphia, PA 19130

**Dr. Tony B. Watlington Sr., Ed.D.**
Superintendent

ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០២២

ជូនចំពោះ ក្រុមគ្រួសារ និងសិស្សានុសិស្សរបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា៖

**សូមស្វាគមន៍មកកាន់ឆ្នាំសិក្សា ២០២២-២០២៣**! នៅថ្ងៃច័ន្ទ ទី ២៩ ខែ សីហា ខ្ញុំទន្ទឹងរង់ចាំឃើញថ្នាក់រៀនរបស់យើងដែលពោរពេញទៅដោយក្មេងៗដែលមានក្តីរំភើប នៅពេលដែលពួកគេជួបជាមួយមិត្តភ័ក្តិ គ្រូថ្មីរបស់ពួកគេ និងចាប់ផ្តើមឆ្នាំដែលមានការធូរស្បើយ មានការរៀនសូត្រ និងការស្វែងយល់ថ្មី មួយឆ្នាំទៀត។

ក្នុងនាមជាអគ្គនាយកក្រសួងអប់រំថ្មី ខ្ញុំនឹងអបអរសាទរ "ថ្ងៃដំបូង" នៃថ្ងៃចូលរៀនដំបូងបង្អស់របស់ខ្ញុំនៅទីនេះ ហើយខ្ញុំរង់ចាំចាប់ផ្តើមដំណើរថ្មីនេះជាដៃគូជាមួយលោកអ្នក។ ខ្ញុំបានចំណាយពេលពីរខែកន្លងមកនេះដើម្បីស្តាប់ និងស្វែងយល់នូវអ្វីៗដែលខ្ញុំអាចធ្វើបានអំពីក្រសួងអប់រំ - អ្វីៗដែលយើងធ្វើបានល្អ និងអ្វីៗដែលយើងអាចធ្វើដើម្បីកែលម្អ។ អ្វីៗដែលខ្ញុំបានឮជាបន្តបន្ទាប់គឺការមានបំណងប្រាថ្នាយ៉ាងមុតមាំក្នុងការធ្វើការជាមួយគ្នាឱ្យកាន់តែល្អឡើង – *ជាដៃគូពិត* – ដើម្បីពន្លឿនលទ្ធផលជោគជ័យសម្រាប់សិស្សទាំងអស់ ទោះបីជាយើងមានការលំបាកក៏ដោយ។ ខ្ញុំជឿថា មធ្យោបាយតែមួយគត់ដែលយើងអាចឆ្ពោះទៅមុខដោយជោគជ័យគឺ*ការរួមគ្នា* ហើយខ្ញុំប្តេជ្ញាធ្វើដូច្នេះ។

សូមប្រាកដថា យើងបានខិតខំរៀបចំសាលារបស់យើង ឱ្យត្រូវនឹងសេចក្តីត្រូវការរបស់កូនលោកអ្នក ក្រោយពីពួកគេមានការលំបាកខ្លាំងក្នុងអារម្មណ៍ និងការសិក្សា ដោយជំងឺកូវីដ និងការប៉ះពាល់ផ្សេងៗទៀតអស់រយៈពេលបីឆ្នាំមកនេះ។ យើងនឹងមានអ្នកអប់រំដែលយកចិត្តទុកដាក់នៅជុំវិញពួកគេ និងការគាំទ្រដល់អារម្មណ៍ដែលមានសារៈសំខាន់ក្នុងការស្តារសុខភាពផ្លូវចិត្ត និងសុខុមាលភាពរបស់ពួកគេ។ យើងនឹងទទួលពួកគេដោយស្វាគមន៍ និងរួមបញ្ចូលក្នុងបរិយាកាសសិក្សាដែលជួយពួកគេឱ្យមានអារម្មណ៍ថាជាមនុស្សមានតម្លៃ និងធ្វើឱ្យសក្តានុពលរបស់ពួកគេក្លាយជាការពិត។ យើងនឹងធ្វើអ្វីៗទាំងអស់នេះនៅក្នុងអគារសិក្សាដែលជ្រះស្អាត ដែលមានម៉ាស៊ីនទឹកសម្រាប់លាងដៃ និងម៉ាស៊ីនសម្រាប់ផឹកទឹក ដោយមិនបាច់យកដៃប៉ះ ម៉ាស៊ីនបន្សុតខ្យល់ និងជំនួយផ្សេងៗទៀតដើម្បីការពារសុខុមាលភាពរបស់អ្នកគ្រប់គ្នានៅក្នុងសាលារបស់យើង។

ម្យ៉ាងវិញទៀត ឆ្នាំសិក្សានេះតំណាងឱ្យការចាប់ផ្តើមថ្មីដ៏គួរឱ្យរំភើបសម្រាប់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា។ លោកអ្នកនឹងបានជ្រាបថែមទៀតនៅក្នុងសប្តាហ៍ និងខែខាងមុខនេះ អំពីឱកាសថ្មីដែលនឹងជម្រាបអំពីជំហានបន្ទាប់របស់ខ្ញុំ រួមទាំងការបង្កើតផែនការយុទ្ធសាស្ត្រប្រាំឆ្នាំដ៏ខ្លាំងក្លា។ ធ្វើយ៉ាងណាត្រូវ ចុះឈ្មោះសម្រាប់ទំព័ររឺបសែសម្រាប់មាតាបិតា ដើម្បីឱ្យលោកអ្នកអាចទទួលព័ត៌មានថ្មីៗ និងការប្រកាសសំខាន់ៗទាំងអស់ នៅពេលគេប្រកាស។

ដើម្បីជួយលោកអ្នកឱ្យរីករាយសប្តាហ៍ចុងក្រោយនេះ មុនមុនពេលចូលរៀនវិញ មិត្តភ័ក្តិរបស់យើងនៅសារមន្ទីរនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា (Philadelphia Museum of Art) អនុញ្ញាតឱ្យបុគ្គលិក និងក្រុមគ្រួសាររបស់យើងឱ្យ **ចូលសារមន្ទីរដោយឥតគិតថ្លៃ នៅថ្ងៃសៅរ៍ ទី ២៧ ខែ សីហា ពីម៉ោង ១០ ព្រឹក ដល់ ៣ រសៀល។** លោកអ្នកអាចចុះឈ្មោះសម្រាប់សំបុត្រចូលរបស់លោកអ្នកនៅ ត្រង់នេះ។

សូមមានឆ្នាំសិក្សាថ្មីដ៏អស្ចារ្យ!

*Tony*

Tony B. Watlington Sr., Ed.D.
អគ្គនាយកក្រសួងអប់រំ
ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា